# <u>ច្បាប់ផ្នែកទីលំនៅដោយស្មើភាពគ្នាសំរាប់ជនដែលមានពិការភាព</u>

## <u>Fair Housing For Persons With Disabilities</u>

ពត៌មានផ្តល់ជូនដោយ
ក្រុមប្រឹក្សាផ្នែកទីលំនៅស្មើភាពគ្នានៃរដ្ឋអូរ៉េហ្គិន
(Fair Housing Council of Oregon)

### ជាទូទៅ

មាត្រាច្បាប់ផ្នែកទីលំនៅស្មើភាពគ្នារបស់សហព័ន្ធនិងរបស់រដ្ឋអូរ៉េហ្គិនការពារជនដែលមានពិការភាពពីការប្រកាន់លក្ខណៈខុសច្បាប់នៅក្នុងផ្នែកទីលំនៅ ។ ច្បាប់ទាំងនេះអនុវត្តទ៍ចំពោះអ្នកផ្តល់ទីលំនៅសាធារណៈនិងឯកជន ។ ច្បាប់សិទ្ធិពលរដ្ឋរបស់សហព័ន្ធឯទៀតការពារជនដែលមានពិការភាពពីការប្រកាន់លក្ខណៈនៅក្នុងកម្មវិធីទីលំនៅដែលឧបត្ថម្ភថវិកាដោយក្រសួងសាធារណៈ និងនៅក្នុងទីកន្លែង ជំនួញ ដូចជាការិយាល័យសំរាប់ជួលជាដើម ។

### តើនរណាដែលត្រូវបានគេការពារចំពោះការប្រកាន់លក្ខណៈដោយយោងលើពិការភាព?

ពិការភាពនៅក្រោមច្បាប់ផ្នែកទីលំនៅស្មើភាពគ្នាត្រូវបានចែងដោយទូលំទូលាយដោយរួមបញ្ចូលទាំងលក្ខណៈផ្នែករាងកាយឬផ្នែកសតិបញ្ញាដែលធ្វើឲ្យអន់ខ្សោយជាខ្លាំងដល់សកម្មភាពសំខាន់ៗក្នុងការរស់នៅ ដូចជាការមើល ការដើរ ការគិត និងអ្វីៗដទៃទៀត ។ ច្បាប់ផ្នែកទីលំនៅស្មើភាពគ្នាការពារអ្នកស្វែងរកទីលំនៅ សមាជិកគ្រួសារ ឬភ្ញៀវ ។ ច្បាប់នេះការពារភាពអន់ខ្សោយពិតប្រាកដ ប្រវត្តិនៃពិការភាព ឬជំនឿដោយភាន់ច្រឡំថាជនម្នាក់ពិការ ។ អ្នកប្រើថ្នាំញៀនបច្ចុប្បន្នមិនត្រូវបានច្បាប់នេះការពារទេ ប៉ុន្តែជនដែលញៀនស្រា ឬនៅក្នុងការលះបង់ការប្រើថ្នាំញៀនហួសកំរិតត្រូវបានច្បាប់នេះការពារ ។

### ការហាមឃាត់ការប្រកាន់លក្ខណៈដោយផ្ទាល់

ការប្រកាន់លក្ខណៈពីព្រោះតែជនម្នាក់ពិការគឺខុសច្បាប់នៅក្នុងប្រភេទទាំងអស់របស់កិច្ចការផ្នែកទីលំនៅ ដូចជា ការជួល ការលក់ផ្ទះ ការឲ្យទិញជឿ ហើយនិងការផ្សាយពាណិជ្ជកម្ម ។ ឧទាហរណ៍នៃការប្រកាន់លក្ខណៈដោយផ្ទាល់ពីព្រោះតែពិការភាពអាចជាការបដិសេធមិនជួលផ្ទះឲ្យជនម្នាក់ដោយសារតែជននោះមានជំងឺធ្ងន់ធ្ងរនិងរ៉ាំរ៉ៃដូចជារោគស្អូត ឬរោគអេដ្ស (AIDS) ។ ទោះយ៉ាងនេះក៏ដោយ ចូរចងចាំថាច្បាប់ផ្នែកជំនួយទីលំនៅស្មើភាពគ្នាអនុវត្តចំពោះអំពើប្រកាន់លក្ខណៈដែលធ្វើឡើង *ព្រោះតែ* ពិការភាព មិនមែនព្រោះតែមូលហេតុស្របច្បាប់ដូចជាមានឈ្មោះមិនល្អក្នុងការជឿជំពាក់ដែលអនុវត្តចំពោះអ្នកដាក់ពាក្យសុំជំនួយទាំងអស់ ។ ច្បាប់ផ្នែកជំនួយទីលំនៅស្មើភាពគ្នាក៏ហាមមិនឲ្យម្ចាស់ផ្ទះសួរសំនួរអំពីពិការភាព លើកលែងតែនៅក្នុងកាលៈទេសៈដែលបានកំរិត ដូចជានៅពេលដែលពិការភាពជាលក្ខណៈសំរាប់កម្មវិធីជំនួយទីលំនៅ ។

### កិច្ចតំរូវលើ "ការចេញចូល" នៅក្រោមច្បាប់ផ្នែកទីលំនៅស្មើភាពគ្នា

គោលបំណងនៃច្បាប់ផ្នែកទីលំនៅស្មើភាពគ្នាគឺដើម្បីធ្វើឲ្យឱកាសនៃការទទួលទីលំនៅមានភាពស្មើគ្នា ។ នៅក្នុងករណីពិការភាព ច្បាប់តំរូវឲ្យអ្នកផ្តល់ទីលំនៅប្រកាន់យកជំហានល្អត្រឹមត្រូវដើម្បីបង្កើនវិធីចូល ។ ការតំរូវទាំងបីយ៉ាងគឺ៖

- **ទីកន្លែងធម្មតាដែលអាចចេញចូលបាន និងអាគារទីលំនៅជាន់ខាងក្រោម "ដែលអាចសំរបសំរួលរួចដោយស្រួល** (readily adaptable) "**នៅក្នុងអាគារល្វែង សំរាប់គ្រួសារ ចំនុះដែលបានកសាងតាំងពីឆ្នាំ 1991 ។** មាត្រាច្បាប់ក៏តំរូវឲ្យមានផ្លូវខាងក្រៅដែលអាចចូលទៅក្នុងអាគារនិងផ្នែកជាន់ក្រោម ហើយនិងកន្លែងធម្មតាដែលអាចចេញចូលបានដូចជាបន្ទប់កំសាន្តជាដើម ។

FAIR HOUSING COUNCIL of Oregon

1020 SW Taylor Street, Suite 700, Portland, Oregon 97205-2512
ទូរស័ព្ទ៖ 503-223-8197 ឬ 1-800-424-3247 (TTY)
បណ្តាញអ៊ិនធើណិត៖ http://www.fhco.org, សារអេឡិកត្រូនិក៖ information@fhco.org
ទូរស័ព្ទបណ្តឹងរបស់ HUD៖ 1-800-877-0246

[Cambodian]

- **ការកែប្រែគំរោងអាគារដើម្បីបង្កើនការចេញចូល ។** អ្នកផ្តល់ទីលំនៅត្រូវតែអនុញ្ញាតិឲ្យអ្នកជួលចេញប្រាក់ផ្ទាល់ធ្វើការកែប្រែគំរោងអាគារ *ដោយសមហេតុផល* ដើម្បីឲ្យអ្នកជួលនោះអាចប្រើទីលំនៅនោះបានសព្វគ្រប់ ។ នៅទីលំនៅដែលឧបត្ថម្ភថវិកាដោយក្រសួងសាធារណៈ ម្ចាស់ផ្ទះអាចត្រូវគេតំរូវឲ្យចេញថ្លៃកែប្រែនោះ ។

- **ការសំរបសំរួលសមហេតុផលនៅក្នុងក្រិត្យវិន័យ ច្បាប់ ការអនុវត្តន៍ ឬកិច្ចបំរើ ។** អ្នកជួលអាចស្នើសុំការសំរបសំរួលមួយ បើវាជាការចាំបាច់ពីព្រោះតែពិការភាព *ហើយទាំង* ចាំបាច់ដើម្បីផ្តល់ឲ្យជននោះនូវឱកាសស្មើភាពគ្នាដើម្បីប្រើ ឬពេញចិត្តនិងទីជំរកនោះ ។ ម្ចាស់ផ្ទះត្រូវអនុញ្ញាតឲ្យតាមសំណូមពរនោះលើកលែងតែការធ្វើដូច្នោះបង្កើតឲ្យមានបន្ទុកដែលមិនអាចទ្រាំទ្របាន ឬកែប្រែជាមូលដ្ឋានជំពុំនូវជំនួញនេះ ។

**សូមទូរស័ព្ទទៅក្រុមប្រឹក្សាផ្នែកទីលំនៅស្មើភាពគ្នារបស់រដ្ឋអូរីហ្គិន (Fair Housing Council of Oregon)តាមលេខ 503-223-8197 ឬ 1-800-424-3247 ដើម្បីរកពត៌មានបន្ថែម ។**

ចូរចងចាំថាច្បាប់ផ្នែកទីនៅស្មើភាពគ្នាក៏ការពារអ្នកពីការប្រកាន់លក្ខណៈពូជសាសន៍ដោយយោងលើ សាសន៍ ពណ៌សំបុរ ជាតិកំណើតដើម សាសនា ភេទ ឋានៈរៀបការ ប្រភពប្រាក់ចំណូល ហើយការមានកូននៅក្នុងគ្រួសាររបស់អ្នក ។

FAIR HOUSING COUNCIL of Oregon

1020 SW Taylor Street, Suite 700, Portland, Oregon 97205-2512
ទូរស័ព្ទ៖ 503-223-8197 ឬ 1-800-424-3247 (TTY)
បណ្តាញអ៊ិនធើណិត៖ http://www.fhco.org, សារអេឡិចត្រូនិក៖ information@fhco.org
ទូរស័ព្ទបណ្តឹងរបស់ HUD៖ 1-800-877-0246

[Cambodian]